

ប្រាសាទអង្គរធំ (រូបថត ទស្សនាវដ្ដី National Geographic)

# ប្រភពដើមនៃស្ថាបត្យកម្ម និងប្រភពដើមរបស់មនុស្សខ្មែរ ដែលជាម្ចាស់នៃប្រាង្គប្រាសាទ

តម្រូវការជាចាំបាច់នូវទីជម្រករបស់គ្រប់សត្វមានជីវិត ជាសភាវគតិ（INSTINCT）ដែលពុំអាចបំបែកបានដែរ សូម្បីតែសត្វមានជីវិតតូចតាច ឬធំមហិមាក៏ត្រូវការចាំបាច់នូវទីជម្រកខានពុំបានឡើយ ទោះបីជម្រកនោះជាកូនច្រកដ៏តូចមួយ ជារូង ជាល្អាង ជាគុហា ជាបង្គង ជាសំបុក ជាខ្ទម ជាភូមិគ្រឹះ ជាបរមរាជវាំង ឬជាប្រាង្គប្រាសាទក្តី ។ សត្វតូចល្អិត ដូចជាសត្វស្រមោច ចង្រិត ក្តាម កង្កែប ហ៊ីង គីង្គក់ ឆ្កែចចក ខ្លា ដំរី ក៏មានលេណដ្ឋាន មានរូងជាទីជម្រករបស់ខ្លួនដែរ ។ រីឯសត្វស្លាបមានសត្វពពេច ចាបព្រាប ខ្លែង ទីទុយ ត្មាត ឥន្ទ្រី ក៏មានសំបុក ឬបង្គងជាជម្រករបស់ខ្លួនដែរ រួមទាំងកណ្តៀរ និងសត្វឃ្មុំ ក៏មានដី ដំបូក និងសំបុកជាទីជម្រករបស់ពួកគេដែរ ដែលមានរចនាសម្ព័ន្ធផ្ទៃក្នុងអគារគួរឱ្យចាប់អារម្មណ៍បំផុត តែទីជម្រកទាំងនោះពុំមានការរីកចម្រើនខាងបច្ចេកទេស និងសំភារៈសាងសង់ឡើយ។ ប្រភេទសត្វ ដែលប្រើប្រាស់នូវសភាវគតិមានបញ្ញាញាណ គឺមនុស្សដែលធ្វើឱ្យវិស័យស្ថាបត្យកម្មមានការរីកចម្រើនតាំងពីពេលមនុស្សរស់នៅក្នុងគុហា រូងភ្នំ ល្អាងភ្នំ ខ្ទម សំណង់ធ្វើពីឈើ ពីថ្ម ពីដែក រហូតដល់មានអគារទំនើបខ្ពស់ៗតាំងពីសម័យអគារ La Tour Eiffel ឬ Eiffel Tower កំពស់ ៣២៤ម៉ែត្រ សាងសង់នៅឆ្នាំ១៨៨៩ នៅទីក្រុងប៉ារីស ប្រទេសបារាំង រហូតមកដល់បច្ចុប្បន្ននេះមានអគារខ្ពស់ៗមួយចំនួនដូចជាអគារនៅតៃប៉ិ ១០១ កំពស់ ៥០៨ម៉ែត្រ សាងសង់នៅតៃវ៉ាន់ នាឆ្នាំ ២០០៤ អគារនៅ Burj Dubai កំពស់ប្រមាណ ៨០០ម៉ែត្រ អគារភ្លោះនៅ Malaysia（៤៥២ម៉ែត្រ = ៨៨ជាន់ សង់នៅឆ្នាំ១៩៩៨）និងគ្រោងសាងសង់នៅសៀងហៃអគារ Bionic Tower មានកំពស់ប្រមាណ ១.២២៨ម៉ែត្រ = ៣០០ជាន់គ្រោងសាងសង់នៅឆ្នាំ ២០១៥, ២០២០ជាដើម ជាកញ្ចក់ឆ្លុះបញ្ចាំងនូវការរីកចម្រើនសំណង់ស្ថាបត្យកម្ម តាមរយៈការរីកចម្រើនខាងបច្ចេកទេស បច្ចេកវិទ្យាទំនើប សិល្បៈនៃការលើកគំរោងស្ថាបត្យកម្មសេដ្ឋកិច្ច និងនយោបាយដឹកនាំប្រទេសជាតិ។

ទាក់ទិននឹងប្រភពដើមកំណើតមនុស្សខ្មែរ បើយោងតាមឯកសារអ្នកប្រាជ្ញបារាំងជាច្រើន មានជាអាទិ៍លោក អៃម៉ូនីញេ（Étienne François Aymonier）បានបញ្ជាក់ថា ប្រភពនៃដើមកំណើតខ្មែរ កើតមានតាំងពីសម័យបុរេប្រវត្តិប្រមាណ ៥.០០០ឆ្នាំមុនគ្រីស្តសករាជ ដោយមានវត្តមានមនុស្សខ្មែរដំបូងបង្អស់ អូម៉ូសាព្យាង ឬហូម៉ូស៊េបពាន（HOMOSAPIENS）ដែលមានការបន្តពូជជាមួយជនជាតិកុលសម្ព័ន្ធ ដែលចុះមកពីជើងភ្នំទីបេ ឬភ្នំហេមពាន្ត（ហ៊ីម៉ាឡាយ៉ា）បានចុះមករស់នៅតំបន់អាស៊ីភាគអាគ្នេយ៍ ដែលបង្កើតបានជាពូជអំបូរមន-ខ្មែរ។

ចំណែកលោក ម៉ូរីហ្សុង (Morizon) បានបញ្ជាក់ថា ប្រជាជនខ្មែរដំបូងប្រហែលជាមានការតួបផ្សំជាមួយប្រជាជនអាំងដូណេស៊ៀន ឬឥណ្ឌូនេស៊្យែន (Indonésiennes) ដែលដំបូងជាងនេះទៅទៀត គឺជនជាតិឥណ្ឌាក្នុងន័យនេះ ប្រជាពលរដ្ឋខ្មែរពិតជាម្ចាស់ទឹកដីនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ហើយពូជសាសន៍ខ្មែរយើងទេ ដែលត្រូវពួកសត្រូវឈ្លានពានលេបទឹកដីតាំងពីសតវត្សទី XIII រហូតមក ។ តាមឯកសារចិន ដែលជាមូលដ្ឋានសម្រាប់អ្នកស្រាវជ្រាវពីប្រវត្តិប្រភពដើមកំណើតប្រជាជាតិខ្មែរ និងនៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ បានបញ្ជាក់ថា កុលសម្ព័ន្ធចោរព្រៃសៀម ដើមឡើយរស់នៅតំបន់យូណាន់ (YUNNAN) ភូមិភាគខាងត្បូងប្រទេសចិន បានចុះមកឈ្លានពានទឹកដីអាណាចក្រខ្មែរនៅភូមិភាគខាងជើងឆៀងខាងលិច នាសតវត្សទី XIII រហូតដល់ខ្មែរយើងត្រូវដកចេញពីរាជធានីអង្គរ នាឆ្នាំ ១៤៣២ ទាំងអស់នេះបញ្ជាក់យ៉ាងច្បាស់ថា គឺជនជាតិសៀមទេ ដែលប្លន់ទឹកដីខ្មែរនោះ។ ស្ថាបត្យកម្មលំនៅឋានខ្មែរ និងស្ថាបត្យកម្មប្រាសាទបុរាណខ្មែរ គឺជាទូទៅគេច្រើនតែលើកតម្កើង និងកោតសរសើរពីស្ថាបត្យកម្មដ៏ធំធេង ប្រកបដោយក្បូរក្បាច់រចនា និងមានភាពអធិកអធម ភាពអធិរាជសម្រាប់ប្រទេសជាតិមួយ ឬសម្រាប់ពូជសាសន៍មួយ តែគេពុំសូវផ្តល់តម្លៃលើស្ថាបត្យកម្មលំនៅឋានរបស់ប្រជាពលរដ្ឋ ដែលជាប្រភពដ៏សំខាន់សម្រាបប់ការកកើតសមិទ្ធផលស្ថាបត្យកម្មដ៏អស្ចារ្យខាងលើនេះទេ ។ តាមពិត វប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ប្រពៃណី ជីវភាពរស់នៅ និងការស្ថាបនាលំនៅឋានរបស់ប្រជាជនទាំងនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការសាងសង់អគារដ៏មានតម្លៃដូចជា ប្រាសាទព្រះវិហារ ប្រាសាទភ្នំបាខែង ប្រាសាទភ្នំក្រោម ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទបន្ទាយស្រី ប្រាសាទ ពារ៉ាមីត Giza (Les Pyramides de Gizeh) របស់ប្រទេសអេហ្ស៊ីប (Egypt) នៅឆ្នាំ២៥៥១ និង ២៤៧២មុនគ្រឹស្តសករាជ ប្រាសាទពារ៉ាមីតកេអុប (La Pyramide de Khéops) នៅឆ្នាំ២៥៥១ និង ២៥២៨មុនគ្រឹស្តសករាជ ប្រាសាទអារតេមីនៅអេហ្វែស (Le temple d' Artémis à Éphèse) ជាដើម។ គ្រប់សកម្មភាពនៃការរស់នៅ និងវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ប្រពៃណី សាសនា និងសកម្មភាពនៃការសាងសង់លំនៅឋានប្រជាជនកម្ពុជាតាំងពីដំបូងរហូតដល់ទីបញ្ចប់ សុទ្ធតែមានឥទ្ធិពលទៅលើការស្ថាបនាប្រាសាទបុរាណរបស់ប្រជាជាតិខ្មែរយើង ដូចជា ការធ្វើពិធីបួងសួងសុំសេចក្តីអនុញ្ញាតពីទេវតាថែរក្សាព្រៃព្រឹក្សា ម្ចាស់ទឹកម្ចាស់ដី ដែលគ្រប់គ្រងភ្នំ ព្រៃ ផ្ទាំងសិលា ដែលមនុស្សខ្មែរតែងតែកាប់ដើមឈើ និងយកថ្មភ្នំមកធ្វើជាសំភារៈសាងសង់លំនៅឋាន និងប្រាសាទខ្មែរជាដើម។ ការគោរពដឹងគុណ

ម្ចាស់ទឹក ម្ចាស់ដី អ្នកតា (LE GÉNIE DE LA TERRE) ដែលជាអ្នកមានគុណផ្តល់នូវសេចក្តីសុខសេចក្តីសប្បាយដល់ប្រជាជនខ្មែរ ពេលមានទឹកជំនន់ ឬពេលមានគ្រោះធម្មជាតិផ្សេងៗ ត្រូវបានប្រជាពលរដ្ឋយើងលើកតំកើងឱ្យខ្ពស់ជាងគេលើទួលដំបូក រួមទាំងមានការសាងសង់ជាខ្ទមសម្រាប់អ្នកតា ក៏មានឥទ្ធិពលទៅលើការជ្រើសរើសទីតាំងសម្រាប់ប្រាសាទបុរាណ ជាទីសក្ការៈរបស់ជនជាតិខ្មែរដែរ ។ "ការសាងសង់លំនៅឋានខ្មែរខ្ពស់ផុតពីដី ជាលទ្ធផលផ្លែផ្កានៃវប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរ" (Contruire en hauteur l' Habitat Khmer est le fruit de la culture, de la civilisation et de la tradition Khmères) ក្រោមសំពាធធម្មជាតិ មានទឹកជំនន់ ធាតុអាកាសត្រូពិក (tropic) ភ្លៀង ហើយមានសំណើម និងការចង់បាននូវរាសីខ្ពស់ ក៏មានឥទ្ធិពលទៅលើការស្ថាបនាប្រាសាទបុរាណខ្មែរឱ្យខ្ពស់ជាងគេនៅលើកំពូលភ្នំ ដែលហៅថា ប្រាសាទភ្នំ តួយ៉ាងដូចជាប្រាសាទព្រះវិហារយើងនេះដែរ ។ ពិធីបញ្ចុះបឋមសិលា ការបញ្ចុះសីមា និង ការបញ្ចុះទ្រព្យសម្បត្តិនៅសសរព្រះកន្លោងសុទ្ធតែមានការអនុវត្តន៍ដូចគ្នាទៅលើសំណង់លំនៅឋាន ឬផ្ទះខ្មែរ និងសំណង់ប្រាសាទបុរាណខ្មែរ ។ គម្រោងផ្ទះខ្មែរដែលកើតចេញពីស្ថាបត្យកម្ម កោសិកាដែលមានរាងជាចតុកោណកែងស្មើ និងចតុកោណកែងក៏មានឥទ្ធិពលទៅលើសំណង់ប្រាសាទបុរាណខ្មែរផងដែរ ។

សូមរំឭកថា ប្រទេសសៀមបានឈ្លានពាន និងកាន់កាប់ទឹកដីកម្ពុជា ដែលស្ថិតនៅក្បែរប្រាសាទព្រះវិហារព្រមទាំងនៅតាមបណ្តាភូមិសាស្ត្រនានាទៀត អស់រយៈពេលជាងមួយឆ្នាំហើយមកដល់ថ្ងៃទី១៩ ខែសីហា គ.ស.២០០៩នេះ ។

ប្រភពព័ត៌មានៈ សារព័ត៌មានកោះសន្តិភាព

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ឯកស័ក ព.ស.៥៥៣ ត្រូវនឹងថ្ងៃទី១៩ ខែសីហា គ.ស.២០០៩

Koh Santepheap News
Wednesday August 19, 2009

www.templenews.info